00878833

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 01 / 2013
ម៉ោង (Time/Heure) : 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E258

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង,

**កម្មវត្ថុ÷** ការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ

កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានទទួលដំណឹងពីមន្ទីរឃុំឃាំង អ.វ.ត.ក ថា ជនជាប់ចោទ នួន ជា នឹងត្រូវបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយសារគាត់មានអាការៈខ្សោយ និងនឿយហត់អស់កម្លាំងធ្ងន់ធ្ងរ។ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះក៏បានទទួលដំណឹងថា ជនជាប់ចោទមានរោគវិនិច្ឆ័យរលាកទងសួតស្រួចស្រាវ ហើយកំពុងស្ថិតក្រោមការតាមដាននៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រហូតដល់មានការជូនដំណឹងបន្ថែមទៀត។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍មួយពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលបានបញ្ជាក់ថាស្ថានភាពសុខភាពទូទៅរបស់ នួន ជា បានធូរស្រាលបន្តិច ប៉ុន្តែកំដៅក្នុងខ្លួនរបស់គាត់នៅខ្ពស់នៅឡើយ និងក្អកជាញឹកញាប់ (ឯកសារ E10/104/1)។ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះក៏បានទទួលដំណឹងថា ជនជាប់ចោទ ខៀវ សំផន ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់សប្តាហ៍នេះ ប៉ុន្តែនឹងទុកស្ថានភាពនេះក្រោមការត្រួតពិនិត្យឡើងវិញ។

00878834

E258

អង្គជំនុំជម្រះក៏បានទទួលផងដែរនូវលិខិតមួយពី ជនជាប់ចោទ នួន ជា ដែលបានបញ្ជាក់ថា គាត់មិនលះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿងលេខ ០០២/០១ នេះឡើយ (ឯកសារ E257)។ ដូច្នេះហើយ អង្គជំនុំជម្រះសម្រេចផ្អាកការកោះហៅសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ជនជាប់ចោទមានលទ្ធភាពអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការដោយផ្ទាល់ ឬតាមរយៈឧបករណ៍សោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១ (៥) ឬក៏ជ្រើសរើសការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅបន្ទប់សវនាការ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនឹងព្យាយាមបន្តកិច្ចដំណើរការនីតិវិធីជាមួយការពិចារណាអំពីលទ្ធភាពនៃការធ្វើសវនាការដេញដោលលើឯកសារ និងការបង្ហាញឯកសារដែលពាក់ព័ន្ធបំផុតសម្រាប់ការបញ្ជាក់ការពិតក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះស្នើសុំឱ្យមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បញ្ជាក់ថា តើ ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានចេតនាក្នុងការលះបង់សិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃការធ្វើសវនាការដេញដោលលើឯកសារនេះដែរឬយ៉ាងណា។ អង្គជំនុំជម្រះនឹងទុកឱកាសទៅមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដើម្បីធ្វើសេចក្តីសន្និដ្ឋានបន្ថែមលើឯកសារនានានៅពេលក្រោយ បន្ទាប់ពីមានការពិគ្រោះយោបល់ក្រោយមកទៀតជាមួយកូនក្តីរបស់ខ្លួន ប្រសិនបើមានសំណើសុំដូច្នេះ។